This translation is out of date. Use it along with the current VIS in English. Visit www.immunize.org/vis for details.



**សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំង**

# ថ្នាំវ៉ាក់សាំង Meningococcal ACWY—MenACWY និង MPSV4៖ *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ជំងឺ Meningococcal គឺជាជំងឺធ្ងន់ធ្ងរ ដែលបង្កឡើងដោយបាក់តេរីមួយប្រភេទហៅថា*Neisseria meningitidis*។ ជំងឺនេះអាចបណ្ដាលឲ្យកើតជំងឺរលាកស្រោមខួរ (ការឆ្លងមេរោគលើស្រោមខួរក្បាល និងឆ្អឹងខ្នង) និងការឆ្លងមេរោគក្នុងឈាម។ ជំងឺ Meningococcal ជាញឹកញាប់ កើតឡើង ដោយគ្មានសញ្ញាព្រមានទេ - សូម្បីតែក្នុងចំណោមមនុស្ស ដែលមានសុខភាពល្អ។

ជំងឺ Meningococcal អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយ:ការប៉ះពាល់ជិតគ្នា (ការក្អក ឬថើប) ឬការប៉ះពាល់រយ:ពេលយូរ ជាពិសេស ក្នុងចំណោមមនុស្ស ដែលរស់នៅក្នុងផ្ទះតែមួយ។

មានបាក់តេរី *N. meningitidis*យ៉ាងហោចណាស់ 12 ប្រភេទ ដែលគេហៅថា "serogroups"។ Serogroups A, B, C, W, និង Y បង្កជំងឺ meningococcal ភាគច្រើន។

អ្នកណាក៏ដោយ អាចកើតជំងឺ meningococcal នេះ ប៉ុន្តែ មនុស្សមួយចំនួន មានហានិភ័យកាន់តែខ្ពស់អាចកើតជំងឺនេះ ក្នុងនោះ រួមមាន៖

- កុមារអាយុក្រោមមួយខួប
- ក្មេងជំទង់ និងមនុស្សពេញវ័យ អាយុពី 16 ឆ្នាំ ដល់ 23 ឆ្នាំ
- មនុស្ស មានបញ្ហាសុខភាពមួយចំនួន ដែលប៉ះពាល់ដល់ប្រព័ន្ធស៊ាំ
- អ្នកសិក្សាមីក្រុបជីវសាស្ត្រ ដែលធ្វើការជាមួយនឹងមីក្រុបញែករបស់*បាក់តេរី N. meningitidis*
- មនុស្ស ដែលស្ថិតក្នុងហានិភ័យ ដោយសារតែមានករណីកើតជំងឺនេះក្នុងសហគមន៍របស់ពួកគេ

សូម្បីតែពេលគេកំពុងព្យាបាលជំងឺនេរ ក៏ជំងឺ meningococcal បានសម្លាប់មនុស្ស 10 ទៅ 15 នាក់ ក្នុងចំណោម 100 នាក់ ដែលកើតជំងឺនេះ។ អ្នកទាំងឡាយ ដែលរស់រានមានជីវិត គឺប្រហែល 10 ទៅ 20 នាក់ ក្នុងចំណោម 100 នាក់ នឹងមានបញ្ហាពិការភាព ដូចជា បាត់បង់ការស្ដាប់ ខូចខាតខួរក្បាល ខូចខាតតម្រងនោម កាត់អវ:យវ: បញ្ហាប្រព័ន្ធប្រសាទ ឬស្លាកស្នាមធ្ងន់ធ្ងរ ដោយសារការវះកាត់ប្ដូរស្បែក។

**ថ្នាំវ៉ាក់សាំង Meningococcal ACWY** អាចជួយបង្ការជំងឺ meningococcal ដែលបង្កឡើងដោយបាក់តេរី serogroups A, C, W, និង Y។ មានថ្នាំវ៉ាក់សាំង meningococcal ផ្សេង ដើម្បីជួយការពារបាក់តេរី serogroup B។

## 2 ថ្នាំ Meningococcal ACWY

មានថ្នាំវ៉ាក់សាំង meningococcal ពីរប្រភេទ ដែលអនុញ្ញាតដោយ Food and Drug Administration (FDA) (រដ្ឋបាលចំណីអាហារ និងឱសថ) សម្រាប់ការពារបាក់តេរី serogroups A, C, W, និង Y៖ គឺ ថ្នាំវ៉ាក់សាំង meningococcal conjugate vaccine (**MenACWY**) និងថ្នាំវ៉ាក់សាំង meningococcal polysaccharide vaccine (**MPSV4**)។

ថ្នាំវ៉ាក់សាំង MenACWY ចំនួនពីរដូស ជាធម្មតា ត្រូវបានណែនាំឲ្យប្រើចំពោះក្មេងជំទង់អាយុពី 11 ដល់ 18 ឆ្នាំ៖ គឺ ដូសទីមួយ នៅអាយុ 11 ឬ 12 ឆ្នាំ ដោយដូសចាក់រំឭក នៅអាយុ 16 ឆ្នាំ។ ក្មេងជំទង់មួយចំនួន រាប់ទាំងអ្នកផ្ទុកមេរោគអេដស៍ គួរទទួលដូសបន្ថែម។ សូមសួររកព័ត៌មានបន្ថែមពីអ្នកផ្ដល់សេវាថែទាំសុខភាពរបស់លោកអ្នក។

ក្រៅពីការចាក់ថ្នាំវ៉ាក់សាំងជាប្រចាំសម្រាប់ក្មេងជំទង់ ថ្នាំវ៉ាក់សាំង MenACWY ក៏ត្រូវបានណែនាំឲ្យប្រើមនុស្សក្នុងក្រុមមួយចំនួនផងដែរ។

- មនុស្ស ដែលស្ថិតក្នុងហានិភ័យ ដោយសារតែមានករណីកើតជំងឺ meningococcal បង្កឡើងដោយបាក់តេរី serogroup A, C, W ឬ Y។
- ជនណា ដែលខូចខាតលំពែង ឬលំពែងត្រូវបានវះកាត់យកចេញ
- ជនណា ដែលមានបញ្ហាប្រព័ន្ធស៊ាំជំកម្រ ដែលគេហៅថា "បញ្ហាខ្វះប្រូតេអ៊ិនខំភ្លីមិន"
- ជនណា ដែលប្រើប្រាស់ថ្នាំ ហៅថា eculizumab (ហៅផងដែរថា Soliris®)
- អ្នកសិក្សាមីក្រុបជីវសាស្ត្រ ដែលធ្វើការជាមួយនឹងមីក្រុបញែករបស់*បាក់តេរី N. meningitidis*
- ជនណា ដែលធ្វើដំណើរទៅ ឬរស់នៅ តំបន់ណាមួយលើពិភពលោក ដែលកើតជំងឺ meningococcal ជាទូទៅ ដូចជា តំបន់នានានៅទ្វីបអាហ្វ្រិក។
- និស្សិតមហាវិទ្យាល័យឆ្នាំទីមួយ ដែលរស់នៅក្នុងកន្លែងនិស្សិតស្នាក់នៅរបស់មហាវិទ្យាល័យ
- យោធិនសហរដ្ឋអាមេរិក

កុមារអាយុពី 2 ទៅ 23 ខែ និងមនុស្ស ដែលមានបញ្ហាវេជ្ជសាស្ត្រមួយចំនួន ត្រូវការថ្នាំវ៉ាក់សាំងច្រើនដូស ដើម្បីទទួលបានការការពារគ្រប់គ្រាន់។ សូមសួរអ្នកផ្ដល់សេវាថែទាំសុខភាពរបស់លោកអ្នក អំពីចំនួននិងពេលវេលាចាក់ដូសថ្នាំវ៉ាក់សាំង និងតម្រូវការក្នុងការចាក់ថ្នាំរំឭក។

**ថ្នាំវ៉ាក់សាំង MenACWY** គឺជាថ្នាំវ៉ាក់សាំងល្អប្រសើរចំពោះមនុស្សក្នុងក្រុមទាំងនេះ ដែលមានអាយុ 2 ខែ ដល់ 55 ឆ្នាំ ដែលបានចាក់ថ្នាំវ៉ាក់សាំង MenACWY ពីមុន ឬដែលរំពឹងថា នឹងត្រូវទទួលថ្នាំវ៉ាក់សាំងច្រើនដូស។

**ថ្នាំវ៉ាក់សាំង MPSV4** ត្រូវបានណែនាំឲ្យប្រើចំពោះមនុស្សពេញវ័យដែលមានអាយុច្រើនជាង 55 ឆ្នាំ ដែលរំពឹងថា នឹងទទួលថ្នាំវ៉ាក់សាំងតែមួយដូសប៉ុណ្ណោះ (អ្នកធ្វើដំណើរ ឬក្នុងអំឡុងពេលមានករណីកើតជំងឺនេះក្នុងសហគមន៍)។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាក់វ៉ាក់សាំងនេះ។

សូមប្រាប់អ្នកដែលផ្តល់ថ្នាំវ៉ាក់សាំងដល់លោកអ្នកៈ

- **ប្រសិនបើលោកអ្នកមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ដែលគំរាមដល់អាយុជីវិត។**
  ប្រសិនបើលោកអ្នកធ្លាប់មានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់អាយុជីវិត បន្ទាប់ពីថ្នាំវ៉ាក់សាំង meningococcal ACWY ដូសមុន ឬប្រសិនបើលោកអ្នកមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំងនេះ លោកអ្នកមិនគួរទទួលថ្នាំវ៉ាក់សាំងនេះទេ។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក អាចប្រាប់លោកអ្នកបាន អំពីធាតុផ្សំនៃថ្នាំវ៉ាក់សាំង។

- **ប្រសិនបើលោកអ្នកមានផ្ទៃពោះ ឬបំបៅដោះកូន។**
  ពុំមានព័ត៌មានច្រើន អំពីហានិភ័យ ដែលថ្នាំវ៉ាក់សាំងនេះអាចបង្កឡើងមកលើស្ត្រីមានផ្ទៃពោះ ឬម្តាយបំបៅដោះកូនទេ។ ថ្នាំវ៉ាក់សាំងនេះ គួរត្រូវបានប្រើប្រាស់ ក្នុងអំឡុងពេលមានផ្ទៃពោះ តែក្នុងករណីត្រូវការថ្នាំវ៉ាក់សាំងនេះជាក់ច្បាស់ប៉ុណ្ណោះ។

ប្រសិនបើលោកអ្នកមានជំងឺឈឺស្រាល ដូចជា ជំងឺផ្តាសាយ លោកអ្នកប្រហែលអាចទទួលបានថ្នាំវ៉ាក់សាំងនៅថ្ងៃនេះ។ ប្រសិនបើលោកអ្នកមានជំងឺឈឺមធ្យម ឬធ្ងន់ធ្ងរ លោកអ្នកគួរប្រហែលរង់ចាំរហូតទាល់តែលោកអ្នកជាសះស្បើយវិញ។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់យោបល់លោកអ្នក។

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលរំខាន អាចកើតមាន។ ជាធម្មតា ផលរំខានទាំងនេះគឺជាផលរំខានស្រាល ហើយអាចបាត់ទៅវិញដោយខ្លួនឯង ក្នុងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្តែ ប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ។

មនុស្សពាក់កណ្តាល ដែលទទួលថ្នាំវ៉ាក់សាំង meningococcal ACWY មាន **បញ្ហាស្រាល** បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង ដូចជា បញ្ហាឡើងក្រហម ឬដំបៅនៅកន្លែងចាក់ថ្នាំវ៉ាក់សាំង។ ប្រសិនបើបញ្ហាទាំងនេះកើតឡើង ជាធម្មតាបញ្ហាទាំងនេះកើតឡើង 1 ឬ 2 ថ្ងៃ។ បញ្ហាទាំងនេះកើតជាទូទៅ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង MenACWY ជាងក្រោយពីចាក់ថ្នាំវ៉ាក់សាំង MPSV4។

មនុស្សមួយភាគរយតូច ដែលទទួលថ្នាំវ៉ាក់សាំង កើតជំងឺគ្រុនក្តៅកម្រិតស្រាល។

**បញ្ហាដែលអាចកើតឡើង ក្រោយពីចាក់ថ្នាំវ៉ាក់សាំងៈ**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេកប្រហែល 15 នាទី បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួល។  សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនអាចឈឺចុកចាប់ខ្លាំងត្រង់ស្មា ហើយពិបាកកម្រើកដៃ នៅពេលចាក់ថ្នាំវ៉ាក់សាំង។ ករណីនេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើងក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅៈ **www.cdc.gov/vaccinesafety/**

Translation provided by the Immunization Action Coalition

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួលហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ — ជាធម្មតា ក្នុងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។
- បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (VICP) (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក**1-800-338-2382** ឬចូលទៅគេហទំព័រ VICP នៅ **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់ សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌល ទប់ ស្កាត់ និង បង្ការជំងឺ ឆ្លង)ៈ
  - ទូរស័ព្ទមកលេខ**1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅគេហទំព័រ CDC នៅ **www.cdc.gov/vaccines**

---

Vaccine Information Statement
**Meningococcal ACWY Vaccines**

03/31/2016

Khmer

42 U.S.C. § 300aa-26

Office Use Only